00241940

D99/3/37

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**សំណុំរឿងលេខ:** ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ.០២)

**ដាក់តម្កល់ជូន:** អង្គបុរេជំនុំជម្រះ

**កាលបរិច្ឆេទដាក់ឯកសារ:** ២៥ វិច្ឆិកា ២០០៨

**ភាគីអ្នកតម្កល់:** មេធាវីរបស់លោក កាំង ហ្កេកអ៊ាវ

**ភាសាដើម:** ភាសាបារាំង

**ប្រភេទឯកសារ:** សាធារណៈ

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 25 / 11 / 2008
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

---

**ចម្លើយរបស់ក្រុមការពារក្ដីទៅនឹងសារណា Amicus Curiae**

---

បញ្ជូនដោយ:

**មេធាវីរបស់ជនត្រូវចោទ លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច**

លោក **ការ សាវុត្ថ**

លោក **François ROUX**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25 / 11 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

បញ្ជូនទៅ:

**ចៅក្រមអង្គបុរេជំនុំជម្រះ**

លោកចៅក្រម ប្រាក់ គឹមសាន ប្រធាន

លោកចៅក្រម Rowan DOWNING

លោកចៅក្រម ប៉ែន ពេជសាលី

លោកស្រីចៅក្រម Katinka LAHUIS

លោកចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

លោក គង់ ពិសី

លោក ហុង គឹមសួន

លោក យ៉ុង ផានិត

លោកស្រី Silke STUDZINSKY

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោក Martine JACQUIN

លោក Philippe CANNONE

## ជូនចំពោះអង្គបុរេជំនុំជម្រះ

## I. សេចក្តីផ្តើម

1. ក្រុមការពារក្តីបានកត់ត្រាទុកនូវសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ប៉ុន្តែយើងខ្ញុំសូមបញ្ជាក់ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់ដល់អង្គបុរេជំនុំជម្រះថា អង្គបុរេជំនុំជម្រះនៅតែចាត់ទុកសារណា Amicus Curiae ថាជាគោលសំខាន់ថ្មីមួយ ប្រសិនបើប្រៀបធៀបទៅនឹងការចាប់ផ្តើមនៃនីតិវិធីបណ្តឹងឧទ្ធរណ៍។ នេះហើយជាមូលហេតុដែលបានធ្វើឲ្យអង្គបុរេជំនុំជម្រះសុំទទួល Amicus Curiae ។

2. ដោយគិតដល់ស្ថានភាពថ្មីៗទាំងនេះ ក្រុមការពារក្តីបានសុំឲ្យរៀបចំឡើងនូវសវនាការជាសាធារណៈមួយ ដើម្បីពិភាក្សាតទល់គ្នាដោយផ្ទាល់មាត់ និងជាសាធារណៈ ជាមួយសហព្រះរាជអាជ្ញា អំពីបញ្ហានៃសហឧក្រិដ្ឋកម្មរួម នៅចំពោះមុខអង្គបុរេជំនុំជម្រះ។

3. ដោយសារអង្គបុរេជំនុំជម្រះបានបដិសេធមិនព្រមទទួលពាក្យសុំរៀបចំសវនាការសាធារណៈនេះ - ដែលពាក្យសុំនេះត្រូវបានប្រឆាំងដោយសហព្រះរាជអាជ្ញា - ក្រុមការពារក្តីសុំផ្តល់នូវកំណត់សំគាល់ដូចតទៅ ទាក់ទងនឹងបញ្ហានេះ ជាចម្លើយទៅនឹងសារណា Amicus Curiae ។

## II. កំណត់សំគាល់របស់ក្រុមការពារក្តី

4. ក្រុមការពារក្តីសង្កេតឃើញថា នៅក្នុងសារណារបស់ខ្លួន លោកសាស្ត្រាចារ្យ Antonio Cassese បានបញ្ជាក់ថា៖ *"ទម្រង់នៃការទទួលខុសចំពោះការប្រព្រឹត្តសហឧក្រិដ្ឋកម្មរួមអាចអនុវត្តបាន <u>តាមករណីសមស្រប</u>នៅអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីធានាចំពោះការទទួលខុស*

*ត្រូវលើការប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរទាំងស្រុង* ***ក្នុងករណីដែលតួនាទីជាក់លាក់របស់អ្នកចូលរួមសកម្មភាពនីមួយៗ ក្នុងគោលបំណងរួមនោះ អាចនឹងត្រូវបិទបាំងដោយវិសាលភាពធំធេង និងភាពស្មុគស្មាញរបស់បទឧក្រិដ្ឋនោះ*** *។"*[1]

5. ក្រុមការពារក្តីយល់ឃើញថា ករណីខាងលើនេះមិនមាននៅក្នុងសំណុំរឿងនេះទេ៖ ដោយសារ ឌុចនិងអ្នកក្រោមបង្គាប់របស់គាត់ បានបញ្ជាក់ដល់សហចៅក្រមស៊ើបអង្កេតយ៉ាងច្បាស់លាស់រួចមកហើយ អំពីតួនាទីរបស់ពួកគាត់ និងអំពីការចូលរួមរបស់ម្នាក់ៗនៅក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋនៅ ស-២១។[2]

6. ដោយហេតុនេះហើយ ក្រុមការពារក្តីចាត់ទុកថា មូលហេតុផ្សេងៗទាំងនោះដែលសហព្រះរាជអាជ្ញាយកមកសំអាងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដើម្បីបង្ហាញថាត្រូវតែអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនៅក្នុងសំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស គឺគ្មានមូលដ្ឋានច្បាប់។ ម្យ៉ាងទៀត មូលហេតុទាំងនោះមានភាពផ្ទុយទៅនឹងការវែកញែករបស់សហព្រះរាជអាជ្ញាផ្ទាល់ខ្លួនដែលថា៖ *"ក្រោមអត្ថន័យនៃពាក្យ "* ***ការទទួលខុសត្រូវរបស់***

---

[1] សារណារបស់លោកសាស្ត្រាចារ្យ Antonio Cassese និងសមាជិកទស្សនាវដ្តីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ កថាខ័ណ្ឌទី២១។ សូមអានផងដែរសារណា Amicus Curiae របស់លោកសាស្ត្រាចារ្យ Kai Ambos ផ្នែកទី I.១ ទំព័រទី៤ ៖ *"អង្គជំនុំជម្រះ [ឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិអតីតប្រទេសយូហ្គោស្លាវី ក្នុងរឿងក្តីរបស់ Tadic] បានយកទ្រឹស្តីនៃការចូលរួមក្នុងឧក្រិដ្ឋកម្មអន្តរជាតិដែលពាក់ព័ន្ធនឹងបរិបទសមូហភាព សាកល និងជាប្រព័ន្ធ ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ម្លោះហើយវាអាចជួយ*<u>*ដោះស្រាយបញ្ហានៃការរកភស្តុតាងមួយនេះបាន ពោលគឺភស្តុតាងដែលជួនកាលពិបាកនឹងរកឲ្យឃើញ តួយ៉ាងភស្តុតាងនៃការចូលរួមរបស់បុគ្គលអ្នកចូលរួមម្នាក់ៗនេះ។*</u>" (គូសបន្ទាត់ពីក្រោមដោយយើងខ្ញុំ)។

[2] សូមអានជាពិសេសកថាខ័ណ្ឌ១៦៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨៖ *"ឌុច ទទួលស្គាល់ជានិច្ចនូវការទទួលខុសត្រូវរបស់គាត់ក្នុងឋានៈជាប្រធានមន្ទីរ ស-២១ ចំពោះឧក្រិដ្ឋកម្មដែលកើតមានឡើង"* និងកថាខ័ណ្ឌ២២ និង២៤ ដែលសង្ខេបតួនាទីរបស់អ្នកក្រោមបង្គាប់សំខាន់ៗរបស់ឌុចនៅ ស-២១។

*ថ្នាក់លើ " (ដកស្រង់ឥតកែប្រែ) ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានគ្របដណ្តប់ទៅលើគ្រប់ការប្រព្រឹត្តអំពើឧក្រិដ្ឋទាំងអស់ដែលបានកើតមាននៅមន្ទីរ ស-២១។ "*[3]

7. ដូច្នេះហើយ ក្រុមការពារក្តីយល់ឃើញថា ការអនុវត្តទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម គឺគ្មានមូលដ្ឋានច្បាប់ទាល់តែសោះ នៅក្នុងសំណុំរឿងនេះ។

8. ម្យ៉ាងទៀត វាជាការសំខាន់ណាស់ដែលគួរតែកត់សំគាល់ថា នៅក្នុងសារណារបស់គាត់ លោកសាស្ត្រាចារ្យ Kai Ambos បានចាត់ទុកថា "**គ្មានមូលដ្ឋានច្បាប់**ដោយសារមូលហេតុផ្សេងៗ" នូវគោលជំហររបស់សហព្រះរាជអាជ្ញាដូចចែងនៅក្នុងកថាខ័ណ្ឌទី៥០ និង៥១ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន និងអំណះអំណាងរបស់គាត់ដែលថា៖ *"គោលបំណងរបស់ច្បាប់ អ.វ.ត.ក ក្នុងការកាត់ទោស "មេដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" និង "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" អាចសម្រេចទៅបាន ប្រសិនបើសហឧក្រិដ្ឋកម្មរួមត្រូវបានអនុវត្ត"*។[4]

9. ក្រុមការពារក្តីសូមលើកឡើងថា គោលបំណងពិតប្រាកដរបស់សហព្រះរាជអាជ្ញាក្នុងការសុំការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនៅក្នុងសំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស គឺប្រហែលដើម្បីបានសេចក្តីសម្រេចមួយដែលនឹងសម្រួលដល់ការអនុវត្តនៃទ្រឹស្តីនេះនៅពេលក្រោយ នៅក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស មុននឹងជនជាប់ចោទនៅក្នុងសំណុំរឿងទាំងឡាយនេះ មានលទ្ធភាពបញ្ជាក់នូវកំណត់សំគាល់របស់ខ្លួន

[3] សូមអានកថាខ័ណ្ឌ៦៩ នៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ លើករណីរបស់លោក កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨។

[4] សូមអានសារណា Amicus Curiae របស់លោកសាស្ត្រាចារ្យ Kai Ambos ផ្នែកទី II.២ ទំព័រទី២៤ និង២៥ (គូសបន្ទាត់ពីក្រោមដោយយើងខ្ញុំ)។

ទាក់ទងនឹងបញ្ហានេះ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។[5] នេះជាការរំលោភជាក់លាក់ទៅលើសិទ្ធិការពារក្ដីរបស់ជនជាប់ចោទទាំងនោះ។

10. នៅក្នុងស្ថានភាពនេះ ការយល់ព្រមទទួលបណ្ដឹងរបស់សហព្រះរាជអាជ្ញា អាចវិភាគបានថាជាការបង្វែរនីតិវិធី។

11. ដោយហេតុនេះហើយ ក្រុមការពារក្ដីសូមស្នើទៅអង្គបុរេជំនុំជម្រះឲ្យបដិសេធមិនទទួលបណ្ដឹងឧទ្ធរណ៍ពីសំណាក់សហព្រះរាជអាជ្ញា។

12. ទោះជាយ៉ាងណាក៏ដោយ ក៏ក្រុមការពារក្ដីកត់សំគាល់ថា សារណា Amicus Curiae បង្ហាញថា មានការសង្ស័យទៅលើលទ្ធភាពអនុវត្តទ្រឹស្ដីសហឧក្រិដ្ឋកម្មរួមនៅចំពោះមុខ អ.វ.ត.ក. ដោយមិនរំលោភទៅលើគោលការណ៍ ពុំមានបទល្មើស បើពុំមានច្បាប់ចែង [*nullum crimen sine lege*] ។ សារណា Amicus Curiae ក៏បង្ហាញជាពិសេសថា ភាពអនុលោមតាមទ្រឹស្ដីសហឧក្រិដ្ឋកម្មរួមប្រភេទទីពីរ[6] និងទីបី[7] នៃគោលការណ៍ខាងលើនេះ នៅមានការជជែកខុសៗគ្នានៅឡើយ។

---

[5] សូមអាន ដីកាស្ដីពីការអនុវត្តទម្រង់នៃការទទួលខុសត្រូវដែលគេហៅថាសហឧក្រិដ្ឋកម្មរួម របស់សហចៅក្រមស៊ើបអង្កេត ចុះនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ ក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (D៩៧ / III) ដែលបានកំណត់ថា ភាគីត្រូវដាក់បញ្ជូននូវកំណត់សំគាល់ទាក់ទងនឹងបញ្ហានេះ នៅមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨។

[6] សូមអានសារណា Amicus Curiae របស់លោកសាស្ត្រាចារ្យ Kai Ambos ដែលយល់ឃើញថាសហឧក្រិដ្ឋកម្មរួមទម្រង់ទីពីរ *"វាគ្រាន់តែកើតមានជាប្រភេទរងនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ នៅពេលវេលាសមស្រប ហើយគេអាចគ្រាន់តែចាត់ទុកថាជនជាប់ចោទបានដឹង និងបានព្យាករដឹងជាមុនគ្រប់គ្រាន់ប៉ុណ្ណោះ។"* (ផ្នែក II.៥)

[7] សូមអានសារណា Amicus Curiae របស់លោកសាស្ត្រាចារ្យ Kai Ambos ដែលច្រានចោលនូវការអនុវត្តនៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមនៅចំពោះមុខ អ.វ.ត.ក។

13. ម្យ៉ាងទៀត ក្រុមការពារក្តីសូមគូសបញ្ជាក់ថា សារណា Amicus Curiae ក៏បានបញ្ជាក់ផង ដែរថា ការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមត្រូវបានច្រានចោលដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ។[8]

14. ដូច្នេះហើយ ក្រុមការពារក្តីសូមស្នើដល់អង្គបុរេជំនុំជម្រះឲ្យរាប់បញ្ចូលគោលសំខាន់ទាំងនោះ ព្រមទាំងគោលសំខាន់ផ្សេងទៀតដែលអនុគ្រោះដល់ជនត្រូវចោទ ដែលបានចែងដោយ សារណា Amicus Curiae ទាំងនោះ។

15. នៅទីបញ្ចប់ ប្រសិនបើអង្គបុរេជំនុំជម្រះចាត់ទុកទ្រឹស្តីសហឧក្រិដ្ឋកម្មរួមថាអាចអនុវត្តបាននៅ ចំពោះមុខ អ.វ.ត.ក. ក្រុមការពារក្តីសូមស្នើជាការបន្ទាប់បន្សំដល់អង្គបុរេជំនុំជម្រះ ឲ្យប្រកាស និងធ្វើការសម្រេចថា បញ្ហានៃការទទួលខុសត្រូវរបស់ **ឌុច** ដោយផ្អែកលើទ្រឹស្តីនេះ ចំពោះការណ៍ដែលបានចែងនៅក្នុងសំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ត្រូវតែសម្រេចនៅដំណាក់កាលការជម្រះអង្គហេតុ ដោយអង្គជំនុំជម្រះសាលាដំបូង។[9]

## ដោយមូលហេតុទាំងអស់នេះ

16. ក្រុមការពារក្តីសូមស្នើដល់អង្គបុរេជំនុំជម្រះដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ឲ្យ៖

ដោយបានឃើញសារណា Amicus Curiae

---

[8] សូមអានសារណា Amicus Curiae របស់លោកសាស្ត្រាចារ្យ Kai Ambos ផ្នែក I.១ ទំព័រទី៧ និង៨ កំណត់សំគាល់លេខ១៧ នៅខាងក្រោមទំព័រ ។ សូមអានផងដែរសារណា Amicus Curiae របស់លោកសាស្ត្រាចារ្យ Antonio Cassese និងសមាជិក ទស្សនាវដ្តីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ កថាខ័ណ្ឌ៧០។

[9] ទាក់ទងនឹងចំណុចនេះ សូមអានឃ្លាពីរចុងក្រោយនៃសេចក្តីសន្និដ្ឋាននៃសារណា Amicus Curiae របស់មជ្ឈមណ្ឌលដើម្បីសិទ្ធិ មនុស្ស និងពហុច្បាប់ នៃសាកលវិទ្យាល័យ Mc Gill ។

00241946



D99/3/37

**បដិសេធ**មិនទទួលបណ្ដឹងរបស់សហព្រះរាជអាជ្ញា។

ជាការបន្ទាប់បន្សំ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា ទ្រឹស្ដីសហឧក្រិដ្ឋកម្មរួមអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក.

**ប្រកាស និង ធ្វើការសម្រេចថា** សេចក្ដីសម្រេចថាតើទម្រង់នៃការទទួលខុសត្រូវនេះត្រូវមានការអនុវត្តឬទេ ចំពោះការណ៍ដែលបានចែងនៅក្នុងសំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក./ក.ស.ច.ស គឺជាតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូង ។

**រក្សាសិទ្ធិគ្រប់បែបយ៉ាង**

| | | |
|---|---|---|
| លោក<br>**ការ សាវុត្ថ**<br><br>លោក<br>François Roux | ភ្នំពេញ | [signature]<br><br>[signature] |
| ឈ្មោះ | ទីកន្លែង | ហត្ថលេខា |